# ការលើកកម្ពស់ជំនាញការយកចិត្តទុកដាក់ ការប្រាស្រ័យទាក់ទង និងការធ្វើទំនាក់ទំនងខាងសង្គម

ការចូលប្រើប្រាស់បាន

CAMBODIAN



LA TROBE UNIVERSITY | Olga Tennison Autism Research Centre

VICTORIA State Government | Health and Human Services

# ការទទួលស្គាល់

រដ្ឋាភិបាលវិចថូរៀ បានផ្តត់ផ្គង់មូលនិធិដល់សកលវិទ្យាល័យ La Trobe (សកលវិទ្យាល័យឡាត្រូប) តាមរយៈមជ្ឈមណ្ឌលស្រាវជ្រាវជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី Olga Tennison (OTARC) ដើម្បីបង្កើតកូនសៀវភៅនេះ។

ដើម្បីទទួលបានការបោះពុម្ពផ្សាយនេះក្នុងទម្រង់ដែលអាចចូលយកបាន សូមផ្ញើអ៊ីម៉េលទៅសុខភាពមាតា និងកុមារ <MCH@dhhs.vic.gov.au>

បោះពុម្ពផ្សាយនៅក្នុងប្រទេសអូស្ត្រាលី ដោយសកលវិទ្យាល័យ La Trobe។

© សកលវិទ្យាល័យ La Trobe ឆ្នាំ២០១៩។

បោះពុម្ពផ្សាយលើកទីមួយ ឆ្នាំ២០១៩។

ការរក្សាសិទ្ធិក្នុងការងារនេះ ត្រូវបានផ្តល់ឱ្យសកលវិទ្យាល័យ La Trobe។

សម្ភារៈនៅក្នុងការងារនេះបានទទួលអាជ្ញាប័ណ្ណ ក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-Non Commercial-Non Derivatives។

សំណួរទាំងឡាយគួរធ្វើឡើងដោយ ផ្ញើអ៊ីម៉េលទៅមជ្ឈមណ្ឌលស្រាវជ្រាវជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី Olga Tennison នៅសកលវិទ្យាល័យ La Trobe University
<SACS.Vic@latrobe.edu.au>

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលវិចថូរៀ 1 Treasury Place មែលប៊ន ក្រោមអាជ្ញាប័ណ្ណពីសកលវិទ្យាល័យ Trobe University។

កន្លែងណាដែលពាក្យ ‘ជនជាតិដើម’ ត្រូវបានយកប្រើ វាសំដៅទៅទាំងជនជាតិដើម និងប្រជាជនរស់នៅតាមកោះ Torres Strait។ ជនជាតិដើមភាគតិចត្រូវបានរក្សាទុក ពេលណាវាជាផ្នែកនៃចំណងជើងនៃរបាយការណ៍ កម្មវិធី ឬសម្រង់។

ISBN 978-1-925947-70-0 (បោះពុម្ព)
ISBN 978-1-76069-107-3 (pdf/អនឡាញ/MS word)
អាចទទួលបានតាមអនឡាញនៅ health.vic - Maternal and child health
<https://www2.health.vic.gov.au/maternal-child-health>
បោះពុម្ពដោយ OTARC (សីហា ២០១៩) (1907406)

# អំពីកូនសៀវភៅនេះ

កូនសៀវភៅនេះត្រូវបានរចនាឡើងសម្រាប់ការប្រាស្រ័យទាក់ទងជាមួយកុមារអាយុរវាង១១ខែ និង៣០ខែ។ ប្រសិនបើអ្នកចង់បានព័ត៌មានបន្ថែម សូមនិយាយទៅកាន់គិលានុបដ្ឋាយិកាសុខភាពមាតា និងកុមារ។

កូនក្មេងកំពុងរៀនជាប្រចាំ។ ពួកគេរៀនពីការប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀត។ ប្រសិនបើកុមារមានការលំបាកចំពោះជំនាញការយកចិត្តទុកដាក់ ការប្រាស្រ័យទាក់ទង និងការធ្វើទំនាក់ទំនងខាងសង្គមរបស់ពួកគេ សមត្ថភាពរបស់ពួកគេ ក្នុងការរៀនពីអ្នកផ្សេងទៀតត្រូវបានរងផលប៉ះពាល់។

ការលំបាកចំពោះការយកចិត្តទុកដាក់ ការប្រាស្រ័យទាក់ទង និងការធ្វើទំនាក់ទំនងខាងសង្គមអាចរាប់បញ្ចូលការថយចុះ មិនញឹកញាប់ ឬដាច់លាប់៖

- ទំនាក់ទំនងតាមរយៈការប្រើភ្នែក
- ការឆ្លើយតបពេលណាហៅឈ្មោះ
- ការចង្អុលដើម្បី 'បង្ហាញ', សម្លឹងតាម
- ការគ្រវីដៃ ទះដៃ និងកាយវិការផ្សេងទៀត
- ការចម្លងតាមអ្នកផ្សេងទៀត
- ការធ្វើពុតលេង
- ការបង្ហាញប្រដាប់ក្មេងលេងទៅអ្នកផ្សេងទៀត
- ការញញឹមដែលចែករំលែក
- ការចែករំលែកអារម្មណ៍។

កុមារម្នាក់ៗគឺខុសគ្នា។

ការប្រើប្រាស់យុទ្ធសាស្ត្រសាមញ្ញ និងមានប្រសិទ្ធភាពដែលសមស្របនឹងចំណាប់អារម្មណ៍និងរបៀបរៀនរបស់ពួកគេ អាចជួយពួកគេអភិវឌ្ឍជំនាញទំនាក់ទំនង និងសង្គម។

mosaic
Monitoring of Social Attention
Interaction and Communication

# មាតិកា


## អំពីកូនសៀវភៅនេះ....3

## ការនិយាយ....6

ឃ្លាំមើល និងមតិយោបល់....6

រៀបរាប់ពីអ្វីដែលកំពុងកើតឡើង....6

បន្លឺសម្លេងពាក្យគន្លឹះ ឧទាហរណ៍៖....6

ការប្រើពាក្យបន្ថែមអ្វីដែលកូនរបស់អ្នកនិយាយ....7

សួរសំណួរ....7

គន្លឹះនិយាយ - តំណភ្ជាប់ជាភាសាអង់គ្លេស....7

## ការបង្ហាញ....8

បង្ហាញពីអ្វីដែលអ្នកចង់ឱ្យកូនរបស់អ្នកធ្វើ....8

និយាយពីអ្វីដែលអ្នកចង់ឱ្យកូនរបស់អ្នកចម្លងតាម....8

ប្រើវត្ថុពិតប្រាកដ....8

ប្រើកាយវិការ និងសកម្មភាព....9

ប្រើរូបភាព....9

គន្លឹះបង្ហាញ - តំណភ្ជាប់ជាភាសាអង់គ្លេស....9

## ការលេង....10

ប្រដាប់ក្មេងលេងដែលលើកទឹកចិត្តដល់ការប្រាស្រ័យទាក់ទង រួមមាន៖....10

ហ្គេមលេងជាមួយគ្នា រួមមាន៖....11

គន្លឹះលេង - តំណភ្ជាប់ជាភាសាអង់គ្លេស....11

## ការច្រៀង....12

បទចម្រៀងដែលសមស្របសម្រាប់មនុស្សគ្រប់វ័យ....12

បទចម្រៀងដែលពាក់ព័ន្ធនឹងការធ្វើចលនា....13

គន្លឹះការច្រៀង - តំណភ្ជាប់ជាភាសាអង់គ្លេស....13

**ការអាន ........................................................................ 14**
សៀវភៅសមរម្យសម្រាប់កុមារអាយុ១២ខែ និងច្រើនជាងនេះ ............................................. 14
សៀវភៅសមរម្យសម្រាប់កុមារអាយុ២៤ខែ និងច្រើនជាងនេះ ............................................. 15
គន្លឹះការអាន - តំណភ្ជាប់ជាភាសាអង់គ្លេស ............................................................ 15
**ព័ត៌មានបន្ថែម - តំណភ្ជាប់ជាភាសាអង់គ្លេស ........................................ 16**
ការត្រួតពិនិត្យជំនាញប្រាស្រ័យទាក់ទង-សង្គម របស់កូនអ្នកនៅផ្ទះ ...................................... 16
សិក្ខាសាលា និងក្រុមគាំទ្រ ........................................................................... 16
ការចូលការចូលប្រើប្រាស់ការគាំទ្រ និងសេវាកម្ម ....................................................... 17
ខ្សែទូរស័ព្ទជំនួយ .................................................................................. 17
**ឯកសារយោង ................................................................... 18**

# ការនិយាយ

ការនិយាយទៅកាន់កូនរបស់អ្នក អាចជួយពួកគេដើម្បីអភិវឌ្ឍ៖

- ការយល់ដឹងពីភាសា
- ការប្រើប្រាស់ភាសា
- វាក្យសព្ទ។

## ឃ្លាំមើល និងមតិយោបល់

ពិភាក្សាអំពីវត្ថុ មនុស្ស សកម្មភាព និងព្រឹត្តិការណ៍ដែលកូនរបស់អ្នកមានចំណាប់អារម្មណ៍។

## រៀបរាប់ពីអ្វីដែលកំពុងកើតឡើង

ពេលលេងជាមួយកូនអ្នក និយាយអំពីអ្វីដែលអ្នកកំពុងធ្វើ។

ឧទាហរណ៍ ខណៈពេល 'កំពុងបញ្ចុកចំណីអាហារ' កូនតុក្កតាទារក និយាយថា 'កូនង៉ាឃ្លាន កូនង៉ាកំពុងញ៉ាំអាហារ'។

និយាយតាមសំឡេង និងពាក្យដែលកូនរបស់អ្នកនិយាយ។

បង្អង់រវាងពាក្យ និងឃ្លា ហើយការរង់ចាំមើលថាតើកូនរបស់អ្នកឆ្លើយតប ឬធ្វើតាមអ្វីដែលអ្នកនិយាយឬអត់។

## បន្លឺសម្លេងពាក្យគន្លឹះ ឧទាហរណ៍៖

- 'មើល **រថភ្លើង**'
- 'វាជា**សត្វឆ្កែ**'
- 'សូមហុច**សៀវភៅ**មកខ្ញុំ'។

## ការប្រើពាក្យបន្ថែមអ្វីដែលកូនរបស់អ្នកនិយាយ

ឧទាហរណ៍ ប្រសិនបើកូនរបស់អ្នក៖

- មិនមានពាក្យ - ប្រើពាក្យតែមួយម៉ាត់ នៅពេលនិយាយជាមួយពួកគេ ឧទាហរណ៍ '**ផឹក**'
- ពាក្យមួយម៉ាត់ - ប្រើពាក្យពីរម៉ាត់ នៅពេលនិយាយជាមួយពួកគេ ឧទាហរណ៍ '**ផឹកទៀត?**'
- ពាក្យពីរម៉ាត់ - ប្រើពាក្យបីម៉ាត់ នៅពេលនិយាយជាមួយពួកគេ ឧទាហរណ៍ '**កូនចង់ផឹក?**'។

## សួរសំណួរ

លើកទឹកចិត្តឱ្យកូនរបស់អ្នកឆ្លើយតបដោយសួរសំណួរ រួចមកបង្អង់។

រូបភាព: និយាយជាមួយខ្ញុំអំពីរឿងរ៉ាវដែលមានរៀងរាល់ថ្ងៃ និងអ្វីដែលខ្ញុំសម្លឹងមើល ហើយចង្អុលទៅ។




រូបភាពមានការអនុញ្ញាតពី បណ្តាញការចិញ្ចឹមកូន <raisingchildren.net.au>។

## គន្លឹះនិយាយ - តំណភ្ជាប់ជាភាសាអង់គ្លេស

និយាយទៅកាន់កូនរបស់អ្នក នៅក្នុងភាសាដែលអ្នកដឹងថាល្អបំផុត។ ព័ត៌មានសម្រាប់ឪពុកម្តាយនៅលើវិបសៃថ៍របស់ក្រសួងអប់រំ និងបណ្តុះបណ្តាលរដ្ឋាភិបាលថ្នាក់រដ្ឋ <http://bit.ly/2XhrIdt>។

ការចិញ្ចឹមកូនដែលនិយាយពហុភាសា និងពីរភាសា នៅលើបណ្តាញការចិញ្ចឹមកូន <http://bit.ly/2Gp02hp>។

# ការបង្ហាញ

ការបង្ហាញ ជួយកុមារដើម្បី៖

- រៀនវិធីថ្មីៗនៃការបញ្ចេញអាកប្បកិរិយា
- បង្កើននូវការយល់ដឹង
- រៀនជំនាញថ្មីៗ។

អ្នកអាចគាំទ្រដល់ការរៀនសូត្រ និងការទំនាក់ទំនងរបស់កូនអ្នកដោយបង្ហាញពួកគេនូវអ្វីដែលអ្នកកំពុងនិយាយ។ មានវិធីមួយចំនួនដែលអ្នកអាចធ្វើដូចនេះបាន។

## បង្ហាញពីអ្វីដែលអ្នកចង់ឱ្យកូនរបស់អ្នកធ្វើ

កុមាររៀនចេះដោយមើលអ្នកដទៃ។ នៅពេលអ្នកទទួលការយកចិត្តទុកដាក់ពីកូនរបស់អ្នក បំបែកកិច្ចការយើតៗ និងផ្តល់ការណែនាំជាជំហាន ដើម្បីឱ្យពួកគេអាចមើលឃើញអ្វីដែលអ្នកកំពុងធ្វើ។

ឧទាហរណ៍ អ្នកអាចបង្ហាញពីរបៀបអានសៀវភៅមួយ ដោយបង្ហាញកូនរបស់អ្នកពីរបៀបបើកទំព័រ។ អ្នកក៏អាចបង្ហាញពួកគេដែរពីរបៀបធ្វើវាដោយខ្លួនឯងដោយណែនាំដៃរបស់ពួកគេផ្ទាល់។

## និយាយពីអ្វីដែលអ្នកចង់ឱ្យកូនរបស់អ្នកចម្លងតាម

អ្នកអាចធ្វើគំរូពាក្យ ឬឃ្លាដោយផ្ទាល់មាត់ ដើម្បីឱ្យកូនរបស់អ្នកយកប្រើ។

ឧទាហរណ៍ ពេលអ្នកផ្តល់អ្វីមួយដល់កូនរបស់អ្នក ចូរនិយាយថា 'សូមអរគុណ'។

## ប្រើវត្ថុពិតប្រាកដ

ការបង្ហាញកូនរបស់អ្នកនូវវត្ថុដែលអ្នកកំពុងនិយាយអំពី អាចជួយពួកគេឱ្យយល់ថាពួកគេមានឈ្មោះ។

ឧទាហរណ៍ ពេលអ្នកនិយាយថា 'សៀវភៅ' អ្នកកាន់សៀវភៅដើម្បីបង្ហាញកូនរបស់អ្នក។

## ប្រើកាយវិការ និងសកម្មភាព

អ្នកអាចជួយកូនរបស់អ្នកឱ្យយល់ដឹងពីអត្ថន័យនៃពាក្យរបស់អ្នក ដោយបន្ថែមកាយវិការ និងសកម្មភាព។ ធ្វើចលនាទាំងនេះឱ្យបានច្បាស់លាស់ ដើម្បីឱ្យកូនរបស់អ្នកសង្កេតឃើញ!

ឧទាហរណ៍ កាយវិការរួមបញ្ចូលទាំងការងក់ក្បាលសម្រាប់ ‘បាទ/ចាស៎’ និងគ្រវីក្បាល សម្រាប់ ‘ទេ’ ការគ្រវីដៃសម្រាប់ ‘លាហើយ’។

## ប្រើរូបភាព

ការបង្ហាញរូបភាពដល់កូនរបស់អ្នកអំពីអ្វីដែលអ្នកកំពុងនិយាយ អាចជួយពួកគេផងដែរឱ្យដើម្បីយល់ដឹងពីន័យនៃពាក្យរបស់អ្នក។

ឧទាហរណ៍ បង្ហាញកូនរបស់អ្នកពីរូបភាពស្បែកជើងរបស់ពួកគេ បន្ទាប់មកបាននិយាយថា ‘ទៅយកស្បែកជើងកូន’។

**រូបភាព៖ ស្វែងយល់ពីខាងក្រៅ ហើយនិយាយជាមួយខ្ញុំ អំពីអ្វីដែលយើងមើលឃើញ។**







រូបភាពមានការអនុញ្ញាតពី បណ្ដាញការចិញ្ចឹមកូន <raisingchildren.net.au>។

## គន្លឹះបង្ហាញ - តំណភ្ជាប់ជាភាសាអង់គ្លេស

អានជំនាញបង្រៀនដល់កុមារ៖ វិធីសាស្ត្រផ្សេងគ្នា សម្រាប់ព័ត៌មានបន្ថែមទៀតអំពីវិធីសាស្ត្រផ្សេងគ្នាដើម្បីបង្រៀនជំនាញដល់កុមារ <http://bit.ly/2KUCHsn> នៅលើបណ្ដាញការចិញ្ចឹមកូន។

# ការលេង

ការលេង បង្រៀនកុមារឱ្យចេះពីរបៀបៈ

- ប្រើសំឡេង សកម្មភាព និងពាក្យ ជាផ្នែកមួយនៃការលេងហ្គេម
- ភ្ជាប់ជាមួយអ្នកផ្សេងទៀត សម្រាប់គោលបំណងសង្គម
- ដោះស្រាយបញ្ហា
- ប្តូរវេនគ្នាលេង។

នៅពេលលេង ចូរធ្វើតាមការនាំមុខរបស់កូនរបស់អ្នក ដោយការចូលរួមជាមួយអ្វីៗក៏ដោយដែលពួកគេកំពុងធ្វើ ឬអ្វីៗដែលពួកគេកំពុងលេងជាមួយ។ នេះធ្វើឱ្យការលេងទៅជាទីរីករាយសម្រាប់ទាំងអ្នក និងកូនរបស់អ្នក។

ការលេងជាមួយប្រដាប់ក្មេងលេង និងហ្គេមជាមួយគ្នា អាចលើកទឹកចិត្តកូនរបស់អ្នកដើម្បីប្រាស្រ័យទាក់ទងជាមួយអ្នក ដោយសួរសុំជំនួយ ការសួរនាំជាច្រើនទៀត ការប្តូរវេនគ្នាលេង ការសម្លឹងមើលអ្នក ការធ្វើសំឡេង ឬការនិយាយពាក្យជាដើម។

## ប្រដាប់ក្មេងលេងដែលលើកទឹកចិត្តដល់ការប្រាស្រ័យទាក់ទង រួមមានៈ

- **ពពុះ** - ផ្លុំពពុះមួយចំនួនដើម្បីឱ្យកូនរបស់អ្នកចាប់លេង។ រង់ចាំមើលប្រសិនបើកូនរបស់អ្នកនឹងសម្លឹងមើលមកអ្នក ធ្វើកាយវិការ ឬប្រើសំឡេង ឬពាក្យដើម្បីប្រាប់អ្នកថា ពួកគេចង់ឱ្យអ្នកផ្លុំពពុះថែមទៀត។
- **មួលបន្ទឹងប្រដាប់ក្មេងលេង និងប្រអប់តន្ត្រី** - រង់ចាំ ហើយមើលថាតើកូនរបស់អ្នកសួរអ្នកដើម្បីសុំជំនួយឬទេ។ សម្គាល់មើលប្រសិនបើពួកគេសម្លឹងមើលមកអ្នក ធ្វើកាយវិការ ឬធ្វើសំឡេងនៅពេលអ្វីមួយកើតមានឡើង។
- **បាល់** - រមៀលបាល់មួយឆ្ពោះទៅកាន់កូនរបស់អ្នក ហើយបន្ទាប់មក លើកទឹកចិត្តឱ្យពួកគេរមៀលវាត្រឡប់មកអ្នកវិញ។
- **ដុំប្លុក**- សង់ប៉មមួយ ហើយគោះវាឱ្យរលំដួល។ តើកូនរបស់អ្នកសម្លឹងមើលមកអ្នក ធ្វើកាយវិការឆ្ពោះទៅរកអ្នក ឬធ្វើសំឡេងមួយឬទេ ? រក្សាដុំប្លុកមួយចំនួនសម្រាប់អ្នក ហើយសម្គាល់មើលថាតើកូនរបស់អ្នកសួររកបន្ថែម ឬទេ។

## ហ្គេមលេងជាមួយគ្នា រួមមាន៖

**Peekaboo** - លើកក្អួយឡើង ហើយនិយាយថា '**តើ (ឈ្មោះកូន)នៅទីណា?**' បន្ទាប់មក ទាញក្អួយចុះដោយបន្លឺសម្លេងរំភើប ហើយនិយាយថា '**Peekaboo**'។ ចូរធ្វើម្តងទៀត។

**ចាក់ក្រឡេក** - លើកដៃទាំងពីររបស់អ្នកឡើងលើនៅចំពោះមុខកូន រួចផ្លាស់ប្តូរដៃមកជាចលនាចាក់ក្រឡេក ហើយព្រមគ្នានោះនិយាយថា '**ចាក់ក្រឡេក ចាក់ក្រឡេក ចាក់ក្រឡេក**'។

**ដេញចាប់ / ខ្ញុំនឹងដេញចាប់កូន** - និយាយ '**ខ្ញុំនឹងដេញចាប់កូន**' ឱ្យបានច្រើនដង ខណៈដែលអ្នករក្សាការផ្លាស់ទីខិតទៅជិតកូនរបស់អ្នក ដោយឈោងដៃរបស់អ្នកទៅមុខអ្នក។

រូបភាព៖ ទៅលេងក្រុមកុមារតូចៗក្នុងតំបន់របស់ខ្ញុំ ហើយសូមហុចចានប្លាស្ទិចមួយ ឬប្រអប់ក្រដាសកាតុងមួយមកខ្ញុំ ហើយមើលភាពស្រមៃរបស់ខ្ញុំនឹងទៅជាផ្តេសផ្តាស





រូបភាពមានការអនុញ្ញាតពី បណ្តាញការចិញ្ចឹមកូន <raisingchildren.net.au>។

## គន្លឹះលេង - តំណភ្ជាប់ជាភាសាអង់គ្លេស

ឌីប្រដាប់ក្មេងលេងហ្គេម ហ្គេមផ្គុំរូបភាព និងសកម្មភាពដ៏សប្បាយរីករាយ និងសម្រាប់ការអប់រំពីបណ្ណាល័យប្រដាប់ក្មេងលេងមួយ! បើកចូលបណ្ណាល័យប្រដាប់ក្មេងលេងអូស្ត្រាលី ដើម្បីស្វែងរកបណ្ណាល័យប្រដាប់ក្មេងលេងដែលនៅជិតអ្នក <https://www.toylibraries.org.au>។

ចូលរួមក្រុមកុមារតូចៗក្នុងសហគមន៍ ឬក្រុមកុមារតូចៗដែលបានគាំទ្រ។ ទាក់ទងមក Playgroup (ក្រុមកុមារតូចៗ វិចថូរៀ) ដើម្បីស្វែងយល់អំពីក្រុមទាំងឡាយមាននៅក្នុងតំបន់របស់អ្នក <http://playgroup.org.au>។

បង្កើនបរិយាកាសរៀនសូត្រតាមផ្ទះរបស់កូនអ្នក ជាមួយនឹងគំនិតទាំងឡាយពីការពិភាក្សាតិចតួច <http://www.smalltalk.net.au> នៅតាមវិបសៃថ៍ មជ្ឈមណ្ឌលស្រាវជ្រាវលើការចិញ្ចឹមកូន។

# ការច្រៀង

ការច្រៀង ជួយកុមារធ្វើឱ្យប្រសើរឡើងដល់៖

- ទំនុកចិត្ត និងអត្តសញ្ញាណ
- ជំនាញប្រាស្រ័យទាក់ទង
- ភាសា
- ការនិយាយ។

ច្រៀងចម្រៀងដែលប្រើពាក្យជួន និងពាក្យផ្ទួនៗគ្នា។

ច្រៀងចម្រៀងដែលធ្លាប់ស្គាល់ ហើយច្រៀងឡើងវិញ ម្ដងហើយម្ដងទៀត។ បន្ទាប់ពីបានច្រៀងចម្រៀងពីរបីដង បង្អង់មួយរយៈ ហើយសម្គាល់មើលដើម្បីឱ្យដឹងថាតើកូនរបស់អ្នកនឹងប្រើរាងកាយ ឬពាក្យរបស់ពួកគេ ដើម្បីប្រាប់អ្នកថាពួកគេចង់ឱ្យអ្នកចម្រៀងបន្តឬទេ។

ដាក់បន្ថែមសកម្មភាព ឬចលនាងាយស្រួល អ្នកអាចជួយកូនរបស់អ្នកឱ្យចម្លងតាមសកម្មភាព ឬចលនារបស់អ្នក។ កាត់បន្ថយជំនួយដែលអ្នកបានផ្ដល់ឱ្យពួកគេបន្តិច ម្ដងៗ រហូតដល់ពួកគេអាចចម្លងសកម្មភាពបានដោយខ្លួនឯង។

ព្យាយាមអង្គុយនៅមុខកូនរបស់អ្នកនៅពេលច្រៀង ធ្វើដូច្នេះដើម្បីឱ្យពួកគេអាចមើលឃើញសកម្មភាពរបស់អ្នក។

យកចេញនូវការរំខានទាំងឡាយ ដូចជាអាយផែត ឬទូរទស្សន៍ ធ្វើដូច្នេះដើម្បីឱ្យពួកគេអាចផ្ដោតអារម្មណ៍លើការធ្វើទំនាក់ទំនងជាមួយអ្នក។

## បទចម្រៀងដែលសមស្របសម្រាប់មនុស្សគ្រប់វ័យ

បទចម្រៀងខាងក្រោមគឺជាភាសាអង់គ្លេស អ្នកអាចចូលទៅកាន់ YouTube ដើម្បីពិនិត្យមើលបទចម្រៀង ហើយហាត់ច្រៀងជាមួយកូនអ្នក។

- This Little Piggy
- Open Shut Them
- Twinkle Twinkle
- Old MacDonald Had a Farm
- Incy Wincy Spider
- Children of the Dreaming
- Inanay។

## បទចម្រៀងដែលពាក់ព័ន្ធនឹងការធ្វើចលនា

(សម្រាប់កុមារអាយុ២៤ខែ និងច្រើនជាងនេះ)

បទចម្រៀងខាងក្រោមគឺជាភាសាអង់គ្លេស អ្នកអាចចូលទៅកាន់ YouTube ដើម្បីពិនិត្យមើលបទចម្រៀង ហើយហាត់ច្រៀងជាមួយកូនអ្នក។

- Hokey Pokey
- Ring-Around-a-Rosey
- Sleeping Bunnies
- Head, Shoulders, Knees and Toes
- Row, Row, Row your boat។

### រូបភាព៖ លេងភ្លេង ហើយច្រៀង និងរាំជាមួយខ្ញុំ។





រូបភាពមានការអនុញ្ញាតពី បណ្ដាញការចិញ្ចឹមកូន <raisingchildren.net.au>។

### គន្លឹះការច្រៀង - តំណភ្ជាប់ជាភាសាអង់គ្លេស

មើល ហើយរៀនបទចម្រៀង និងពាក្យចួនពេញនិយមរបស់កុមារ និងសម្រាប់កុមារតូចៗនៅតាមទំព័រវ៉ិបសៃថ៍របស់បណ្ដាញការចិញ្ចឹមកូន ទារកខារ៉ាអូខេ <http://bit.ly/2IzXCy4>។

មើល ហើយរៀនពាក្យចួនពេញនិយមសម្រាប់កុមារតូចៗ ជាភាសាជនជាតិដើម និងប្រជាជនរស់នៅតាមកោះ Torres Strait អាចរកបាននៅតាមវ៉ិបសៃថ៍ first5forever <http://bit.ly/2Zdqlyr> ។

មើល ខារ៉ាអូខេជនជាតិដើម Inanay - ជាមួយទំនុកខ្លីៗ
<https://raisingchildren.net.au/guides/baby-karaoke/inanay-with-lyrics>

# ការអាន

ការអាន ជួយគាំទ្រកុមារខាង៖

- ការអភិវឌ្ឍខួរក្បាល និងការយល់ដឹង
- ជំនាញភាសា និងវាក្យសព្ទ
- ការយល់ដឹងពីអារម្មណ៍។

អានសៀវភៅដែលមានពាក្យចួនគ្នាល្អ កំណាព្យខ្លីៗ ហើយមានពាក្យផ្ទួនៗគ្នា និងងាយស្រួលអាន។

មើលដើម្បីឱ្យឃើញរូបភាពអ្វីដែលកូនរបស់អ្នកសម្លឹងមើល ហើយដាក់ហៅឈ្មោះវត្ថុនោះ។

សួរសំណួរសាមញ្ញៗអំពីរូបភាព ដូចជា 'តើសត្វឆ្កែនៅឯណា? ' ហើយមើលឱ្យឃើញថាតើកូនរបស់អ្នកចង្អុល ឬធ្វើកាយវិការ។

បង្អង់បន្តិចមុននឹងនិយាយ ឬអានពាក្យ ឬឃ្លាជាក់លាក់ណាមួយនៅក្នុងសៀវភៅ ដើម្បីឱ្យបានឃើញថាតើកូនរបស់អ្នកនឹងបញ្ចប់ពាក្យ ឬឃ្លានោះឬទេ។

ធ្វើតំណភ្ជាប់ទៅនឹងចំណង់ចំណូលចិត្តរបស់កូនអ្នក អនុញ្ញាតឱ្យពួកគេជ្រើសរើសយកសៀវភៅមួយនៅក្នុងបណ្ណាល័យ។ បង្ហាញសៀវភៅពីរដល់ពួកគេឱ្យជ្រើសរើស ប្រសិនបើគេមានការលំបាកក្នុងការធ្វើការសម្រេចចិត្ត។

## សៀវភៅសមរម្យសម្រាប់កុមារអាយុ១២ខែ និងច្រើនជាងនេះ

- 'នេះមិនមែនជា ....របស់ខ្ញុំទេ' សៀវភៅ
- ប្រទះឃើញសៀវភៅ
- តើសត្វចៀមបៃតងនៅទីណា?

## សៀវភៅសមរម្យសម្រាប់កុមារអាយុ២៤ខែ និងច្រើនជាងនេះ

- Brown Bear, Brown Bear ( ខ្លាឃ្មុំពណ៌ត្នោត ខ្លាឃ្មុំពណ៌ត្នោត )
- The Very Hungry Caterpillar ( ដង្កូវមេអំបៅដ៏ឃ្លាន )
- Wombat Stew ( សម្លរបស់សត្វ វុំប៊ែត )
- How the birds got their colours ( តើសត្វបក្សីទទួលបានពណ៌របស់ពួកគេដោយបែបណា )
- Big rain coming ( ភ្លៀងធំមកដល់ហើយ )

### រូបភាព: អានសៀវភៅជាមួយខ្ញុំ។ ជួយខ្ញុំឱ្យចេះកាន់សៀវភៅ និងបើកទំព័រ។






រូបភាពមានការអនុញ្ញាតពី បណ្តាញការចិញ្ចឹមកូន <raisingchildren.net.au>។

## គន្លឹះការអាន - តំណភ្ជាប់ជាភាសាអង់គ្លេស

អញ្ជើញទៅបណ្ណាល័យក្នុងតំបន់របស់អ្នក ដើម្បីរកខ្ចីសៀវភៅកុមារមួយចំនួនដោយឥតគិតថ្លៃ ឬចូលរួមក្នុងវគ្គនិទានរឿង។ បើកចូល បណ្ណាល័យសាធារណៈ វិចថូរៀ ដើម្បីរកមើលបណ្ណាល័យមួយដែលនៅក្បែរអ្នក <http://publiclibrariesvictoria.net.au>។

អានគន្លឹះមួយចំនួនដើម្បីចែករំលែកសៀវភៅជាមួយទារក និងកុមារវ័យក្មេង នៅតាម បណ្តាញការចិញ្ចឹមកូន <http://bit.ly/2Ghydq4>។

# ព័ត៌មានបន្ថែម - តំណភ្ជាប់ជាភាសាអង់គ្លេស

## ការត្រួតពិនិត្យជំនាញប្រាស្រ័យទាក់ទង-សង្គម របស់កូនអ្នកនៅផ្ទះ

ASDetect <http://asdetect.org>
កម្មវិធីទូរស័ព្ទដៃឥតគិតថ្លៃដែលឪពុកម្ដាយ និងអ្នកថែទាំអាចប្រើប្រាស់បានដើម្បីតាមដានចំណុចសំខាន់ៗផ្នែកប្រាស្រ័យទាក់ទង-សង្គមរបស់កុមារ និងសញ្ញាដំបូងនៃជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី។

ធនធានបន្ថែមសម្រាប់ឪពុកម្ដាយ អាចរកបាននៅតាមវិបសៃថ៍របស់សកលវិទ្យាល័យ La Trobe អំពីការរកឃើញសញ្ញាដំបូងនៃជំងឺអូទីហ្សឹម <http://asdetect.org/for-parents>

ព័ត៌មានអំពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី

Amaze (Autism Victoria) <https://www.amaze.org.au>
អង្គការកំពូលសម្រាប់ជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតីក្នុងរដ្ឋវិចថូរៀ ផ្ដល់ជូនព័ត៌មាន និងធនធានតភ្ជាប់សម្រាប់បុគ្គលម្នាក់ៗផ្ទាល់ ក្រុមគ្រួសារ និងអ្នកជំនាញទៅកាន់ការគាំទ្រសម្រាប់ជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី។

ការយល់ដឹងអំពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតីអូស្ត្រាលី
<https://www.autismawareness.com.au>
ការអប់រំ និងការយល់ដឹងពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតីរបស់អង្គការមិនរកប្រាក់ចំណេញ។

ការផ្សព្វផ្សាយតាមរយៈផដខាស្ត ស្ដីពីវិសាលគមការចិញ្ចឹមកូន
<https://www.abc.net.au/radio/programs/the-parenting-spectrum>

បណ្ដាញការចិញ្ចឹមកូន <https://raisingchildren.net.au> ព័ត៌មានផ្អែកលើការស្រាវជ្រាវអំពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី និងការអភិវឌ្ឍទូទៅរបស់កុមារ។

ការយល់ដឹងពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី ខ្សែវីដេអូខ្លីមួយអំពីក្មេងប្រុសម្នាក់ឈ្មោះ Ned បង្កើតឡើងដើម្បីជួយដល់ក្រុមគ្រួសារជនជាតិដើម និងប្រជាជនរស់នៅតាមកោះ Torres Strait ឱ្យបានយល់ដឹង និងសម្គាល់ដឹងពីសញ្ញាដំបូងនៃជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី។ <https://www.youtu.be/bQcWvYi5EqY>

## សិក្ខាសាលា និងក្រុមគាំទ្រ

ថ្ងៃដំបូង <https://www.amaze.org.au/support/early-days>
Amaze មានសិក្ខាសាលាឥតគិតថ្លៃអំពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី។

PlayConnect <https://playgroupaustralia.org.au/national-programs/playconnect>
បណ្ដាញក្រុមកុមារតូចៗដែលមានជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតីជាក់លាក់ Playgroup Australia (ក្រុមកុមារតូចៗ អូស្ត្រាលី)។

ពេលវេលារបស់ខ្ញុំ <https://www.mytime.net.au>
កម្មវិធីការគាំទ្រឪពុកម្ដាយ និងអ្នកថែទាំកុមារពិការ ការយឺតយ៉ាវលើការអភិវឌ្ឍ ឬជំងឺរ៉ាំរ៉ៃ។

## ការចូលការចូលប្រើប្រាស់ការគាំទ្រ និងសេវាកម្ម

ការធ្វើអន្តរាគមន៍បានមុនពេល៖ សម្រាប់ព័ត៌មានអំពីសេវាកម្មបញ្ជូន និងការគាំទ្រ ហើយនិងសិទ្ធិទទួលបាន NDIS សូមទំនាក់ទំនងជាមួយការិយាល័យដៃគូ Early Childhood Early Intervention (ការធ្វើអន្តរាគមន៍បានមុនពេលសម្រាប់កុមារតូចៗ( (ECEI) ក្នុងតំបន់របស់អ្នក <https://www.ndis.gov.au/about-us/locations.html#vic>

កម្មវិធីមន្ត្រីសម្របសម្រួលការធ្វើអន្តរាគមន៍បានមុនពេលសម្រាប់ជនជាតិដើម និងប្រជាជនរស់នៅតាមកោះ Torres Strait (EIILO) <https://www.eiilo.com.au> ផ្តល់ជូនក្រុមគ្រួសារនៅក្នុងសហគមន៍ជនជាតិដើម និងប្រជាជនរស់នៅតាមកោះ Torres Strait ជាមួយឧបករណ៍ ភាសា និងព័ត៌មាន ដើម្បីធានាថាពួកគេមានទំនុកចិត្ត ដើម្បីទៅជួបវេជ្ជបណ្ឌិត ឬពេទ្យកុមារ។

មគ្គុទ្ទេសការព្យាបាលពី បណ្តាញការចិញ្ចឹមកូន <https://raisingchildren.net.au/autism>

Therapy Connect <http://www.therapyconnect.amaze.org.au>

## ខ្សែទូរស័ព្ទជំនួយ

សេវាកម្មទីប្រឹក្សាផ្តល់ព័ត៌មានរបស់ Amaze អំពីជំងឺអូទីហ្សឹម ឬជំងឺខ្វះការផ្ចង់ស្មារតី៖ **1300 308 699**

ខ្សែទូរស័ព្ទអំពីសុខភាពមាតា និងកុមារ៖ **13 22 29**

ខ្សែទូរស័ព្ទសម្រាប់មាតាបិតា៖ **13 22 89**

# ឯកសារយោង

ប្រភពខាងក្រោមនេះ ត្រូវបានយកប្រើក្នុងការបង្កើតកូនសៀវភៅនេះ។


Barbaro, J. & Dissanayake, C. (2013). Early markers of Autism Spectrum Disorders in infants and toddlers prospectively identified in the Social Attention and Communication Study (SACS). Autism: International Journal of Research and Practice, 17, 64-86.

Barbaro, J. & Dissanayake, C. (2010). Prospective identification of Autism in infancy and toddlerhood using developmental surveillance: The Social Attention and Communication Study (SACS). Journal of Developmental and Behavioral Pediatrics, 31, 376-385.

Sussman, F. (1999). More than words. Toronto: The Hanen Centre.

Rogers, S., Dawson, G. and Vismara, L. (2012). Early start for your child with autism. New York: Guilford Publications.

ASDetect <http://asdetect.org>

សូមកូននិយាយជាមួយខ្ញុំ <http://www.talkwithmebaby.org>

បណ្ដាញការចិញ្ចឹមកូន <https://raisingchildren.net.au>


mosaic Monitoring of Social Attention Interaction and Communication